

# ព្រះយេស៊ូវបានមានព្រះបន្ទូលថាឲ្យយើងស្រឡាញ់អ្នកជិតខាងរបស់យើង

ថ្ងៃមួយ មានបុរសម្នាក់បានទូលសួរព្រះយេស៊ូវថា តើបទបញ្ញត្តិអ្វីដែលធំជាងគេ ។ ព្រះយេស៊ូវបានមានបន្ទូលថាបទបញ្ញត្តិធំទីមួយ គឺស្រឡាញ់ព្រះ ។ បន្ទាប់មកទ្រង់បានមានបន្ទូលថាបទបញ្ញត្តិទីពីរគឺ « ត្រូវឲ្យស្រឡាញ់អ្នកជិតខាងដូចខ្លួនឯង » ( ម៉ាកុស ១២:៣១ ) ។ បទបញ្ញត្តិនោះមានន័យថា យើងគួរតែស្រឡាញ់គ្នាទៅវិញទៅមក ហើយប្រព្រឹត្តចំពោះពួកគេតាមរបៀបដែលយើងចង់ទទួលបាន ។●

ប្អូនអាចអានដំណើររឿងនេះនៅក្នុង ម៉ាកុស ១២:២៨-៣១ ។



កុមារមួយក្រុមនេះនៅ **រដ្ឋមីស៊ីស៊ីពី ស.រ.អា.** បានជួយសម្អាតផ្ទះរបស់អ្នកជិតខាងរបស់ពួកគេបន្ទាប់ពីមានខ្យល់ព្យុះ ។

## ខ្ញុំអាចស្រឡាញ់អ្នកជិតខាងរបស់ខ្ញុំ

- សូមគិតពីវិធីមួយដែលប្អូនអាចជួយដល់អ្នកជិតខាងម្នាក់ ។
- សូមអធិស្ឋាន ហើយរៀបផែនការមួយដើម្បីជួយពួកគេ ។
- សូមអនុវត្តតាមផែនការរបស់ប្អូន !



សូមកាត់កាតនេះចេញដើម្បីជាការរំឭកដល់ប្អូនឲ្យបន្តជួយដូចជាព្រះយេស៊ូវ ។

តើប្អូនកំពុងតែព្យាយាមជួយអ្នកដទៃដូចជាព្រះយេស៊ូវបានធ្វើដោយរបៀបណា ? សូមសរសេរ ហើយប្រាប់មកពួកយើង ។